# កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា
# សម្លេងយុត្តិធម៌ៈ អំពីប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន

នាងខ្ញុំឈ្មោះជិន សាវីន សព្វថ្ងៃជានិស្សិតប្រវត្តិវិទ្យាឆ្នាំទី៣នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ នាងខ្ញុំមានស្រុកកំណើតនៅភូមិត្រពាំងនប់ ឃុំក្រាំងម្កាក់ ស្រុកអង់ស្នួល ខេត្តកណ្តាល។

តាមរយៈការស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា អំពីការអត់ឃ្លាន ដែលកើតមានឡើងនៅក្នុងរបបខ្មែរក្រហម។ តាមរយៈកម្មវិធីវិទ្យុនេះ នាងខ្ញុំសង្កេតឃើញថា ការអត់ឃ្លានរបស់ប្រជាជន បានរីករាលដាលពេញប្រទេសកម្ពុជា។ បញ្ហានេះ បានប៉ះពាល់ទៅនឹងសិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់របស់មនុស្ស។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានលក្ខខណ្ឌរស់នៅសមរម្យទាំងសុខុមាលភាព និងសុវត្ថិភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ ដោយក្នុងនោះរាប់បញ្ចូលទាំងចំណីអាហារ។ ចំណុចមួយទៀត ដែលនាងខ្ញុំចាប់អារម្មណ៍ និងមានការងឿងឆ្ងល់ "តើមេដឹកនាំនៅក្នុងរបបខ្មែរក្រហម បានដឹងអំពីការអត់ឃ្លានរបស់ប្រជាជនដែររឺទេ"?

ជាចុងបញ្ចប់ក្នុងនាមនាងខ្ញុំជាអ្នកសិក្សាប្រវត្តិសាស្ត្រ នាងខ្ញុំមិនចង់ឱ្យមានប្រវត្តិសាស្ត្របែបនេះកើតឡើងនៅក្នុងប្រទេសកម្ពុជាទៀតទេ។ ជាសំណូមពររបស់នាងខ្ញុំសូមឱ្យមានការស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ និងលុបបំបាត់អំពើអត់ឃ្លាននៅកម្ពុជាឱ្យអស់ ហើយនឹងដាក់ទោសខ្មែរក្រហមឱ្យឆាប់។